**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚៚៚❋៛៛៛៛

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

*ថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២*

# សេចក្តីជូនព័ត៌មាន

នារសៀលថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានទទួលជួប សម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវបណ្ឌិត **Im Jeong Hee** អនុប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ដែលអញ្ជើញមកបំពេញបេសកកម្មផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ។ គោលបំណងនៃកិច្ចប្រជុំគឺពិភាក្សាអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូរបស់ KOICA នៅកម្ពុជា ។

ឯកឧត្តមរដ្ឋមន្ត្រី **ឈៀង យ៉ាណារ៉ា** បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះ លោកជំទាវបណ្ឌិត **Im Jeong Hee** និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូដ៏រឹងមាំរបស់រដ្ឋាភិបាល និងប្រជាជនកូរ៉េ ដែលបានផ្តល់ការគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មរបស់ទីភ្នាក់ងារ KOICA ដែលបាននឹងកំពុងបន្តផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្តគម្រោងយ៉ាងច្រើន ជាពិសេសការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការផ្តល់ជំនួយជាសម្ភារវិជ្ជសាស្ត្រដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ។ បន្ថែមលើនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានជម្រាបជូនភាគីកូរ៉េ អំពីក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣ ដែលផ្តោតសំខាន់លើសសរស្តម្ភ ៣ គឺ÷ ទី១). ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ, ទី២).ការកែទម្រង់ ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន ពិពិធកម្ម និងភាពប្រកួតប្រជែង និងទី៣). ការពង្រឹងភាពធន់ប្រកបដោយចីរភាព និងបរិយាប័ន្ន ។

លោកជំទាវបណ្ឌិត **Im Jeong Hee** បានបង្ហាញអារម្មណ៍សោមនស្សរីករាយក្រៃលែងដែលបានមកមកបំពេញបេសកកម្មនៅកម្ពុជា និងបានចូលរួមសម្ពោធដាក់ឱ្យដំណើរការមជ្ឈមណ្ឌលព្យាបាលជំងឺត្រចៀក ច្រមុះ បំពង់ក នៅក្នុងមន្ទីរពេទ្យព្រះអង្គឌួង ដែលជាហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋកូរ៉េ នាថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ ។ **លោកជំទាវបណ្ឌិត** បានសម្តែងការកោតសរសើរចំពោះកិច្ចសហការដ៏ល្អរបស់ក្រុម

ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយបានបញ្ជាក់ជំហរបន្តគាំទ្រដល់កម្ពុជា ដែលជាប្រទេសអាទិភាពខ្ពស់ក្នុងកិច្ចសហប្រតិបត្តិការ ។ បន្ថែមលើនេះ **លោកជំទាវបណ្ឌិត** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលសម្រេចបានសមិទ្ធផលយ៉ាងធំធេងរហូតមកដល់បច្ចុប្បន្ន និងការដាក់ចេញនូវវិធានការយ៉ាងមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យដ៏ត្រចះត្រចង់រហូតឈានដល់ការបើកប្រទេសឱ្យដំណើរការឡើងវិញលើគ្រប់វិស័យ ។ ចាប់តាំងពីឆ្នាំ១៩៩១ ដល់ឆ្នាំ២០២១ KOICA បានបើកផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ ៣១៦ លានដុល្លារអាមេរិក សម្រាប់វិស័យអាទិភាពសំខាន់ៗ ចំនួន ៤ គឺ÷ អប់រំ, ដឹកជញ្ជូន, អភិវឌ្ឍន៍(ជនបទ)តាមតំបន់, ការគ្រប់គ្រងទឹក និងសុខមាលភាពសាធារណៈ ។ គួរឱ្យកត់សម្គាល់ឃើញថា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ ទំហំហិរញ្ញប្បទានដែលសាធារណរដ្ឋកូរ៉េបានបើកផ្តល់ដល់កម្ពុជាមានការកើនឡើង ហើយទំហំហិរញ្ញប្បទាននេះនឹងបន្តកើនឡើងថែមទៀតនាពេលអនាគត ។

ជាចុងបញ្ចប់ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងអំណរគុណ និងជូនពរលោកជំទាវបណ្ឌិត **Im Jeong Hee** ឱ្យទទួលបានជោគជ័យក្នុងការបំពេញបេសកកម្មនៅកម្ពុជា និងអរគុណដល់ KOICA ដែលបន្តការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការស្តារប្រទេសឡើងវិញពិសេសក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ។

-------------------------